# គុណ្ហីភាពរាត្រី

ធម្មជាតិនិទ្រាស្ងាត់ជ្រងំ
មាន់រងាវយំព្យួលស្វើយ
ខ្យល់បក់ធាងដូងយោលទន់ដើយ
រំភើយបក់ផាត់ក្លិនម្លិះលា។

ព្រះច័ន្ទឈៀងគងភ្នំខ្មៅវែង
មេឃខ្ពស់ធំធេងវែងស្អាតថ្លា
សន្សើមប្រោះព្រំចុងព្រឹក្សា
ហៅសែនសុខាក្នុងរាត្រី។

តែក្នុងចិត្តខ្ញុំមានកង្វល់
រួតរឹតគិតដល់ត្រួយនារី
រូបនាងឌូតតាមគ្រប់ទិសទី
នាំឱ្យវក់វីអស់អង្គកាយ។

ព្រលឹងស្រមៃមើញវរលក្ខណ៍
មានភ័ក្ត្រញញឹមស្រស់ពព្រាយ
ថែមព្យសម្តីនាងនិយាយ
ទ្បែបខាយពិរោះជាប់ពិសម័យ។

ដូចឃ្មុំស្រវឹងក្លិនបុប្ផា
ហើយហើរឆ្មៀវឆ្វាកណ្តាលថ្ងៃ
ខ្លួនបងស្រវឹងនឹងមាសថ្លៃ
នឹករកមមៃគ្មានពេលលស់។

ជន្លេនម្តេចហ៊ានស្រលាញ់ផ្កាយ
ខ្លួនទាបតូចឆ្ងាយម្តេចឈោងខ្ពស់
ម្តេចមិនមើលទ្រព្យមើលសក្តិយស
សញ្ជាតិទាំងអស់សុទ្ធខុសគ្នា។

គ្មានអ្វីគួរឱ្យសង្ឃឹមបាន
ស្រលាញ់បំពាននាំខ្លោចផ្សា
គប្បីខំប្រឹងតែសិក្សា
សម្រេចកាលណាទើបហៅគាប់។

តែទោះគិតឃើញត្រូវដូចម្តេច
ស្នេហាពន្លិចសង្កត់ជាប់
ឱ  ខ្លួនខ្ញុំអើយសែនអភ័ព្វ
ទុក្ខច្រើនស្រទាប់អ្វីម្ល៉េះទេ។

ធម្មជាតិដេកលក់ដោយសុខុម
មាត់មាន់រងំដូចបំពេរ
ខ្យល់ច្រានធាងដូងឱ្យយោលទេរ
ជួយបក់បំបែរក្លិនចំប៉ា។

លោកខែលិចក្រោយភ្នំខ្មៅស្ទើង
ពពកមីរទ្បើងក្នុងមេឃា
សន្សើមស្រោចស្រពពសុធា
ហៅសែនវេទនាក្នុងចិន្តា។

នូ   ហាច

Khmer Story Lovers